00648640

E55/1

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់អ្នកស្រី អៀង ធីរិទ្ធ

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១ ខែ មីនា ឆ្នាំ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ / Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតបរបស់មេធាវីការពារក្ដី អ្នកស្រី អៀង ធីរិទ្ធនៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាចំពោះបណ្ដឹងជំទាស់ទៅក្រុមជម្រះរបស់ អៀង ធីរិទ្ធ, អៀង សារី និង នួន ជា**

---

<u>ដាក់ដោយ៖</u>

**សហមេធាវីរបស់ អៀង ធីរិទ្ធ**

កញ្ញា Diana ELLIS QC

<u>ផ្ញើជូន៖</u>

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម ធូ មណី

ចៅក្រម យ៉ា សុខន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

<u>ផ្ញើជូន៖</u>

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

ពេជ្រ អង្គ

Elisabeth SIMONNEAU FORT

**ឯកសារបានទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 01 / 03 / 2011
ម៉ោង (Time/Heure): 11:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

## I. សេចក្តីផ្តើម និង សំណើសុំ

១. នៅថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ២០១១ មេធាវីការពារក្តី អ្នកស្រី អៀង ធីរិទ្ធ (**ជនជាប់ចោទ**) បានដាក់ពាក្យបណ្តឹង "បណ្តឹងជំទាស់ចៅក្រម នីល នុន, Silyvia Cartwright, Jean-Marc Lavergne, ចៅក្រម យ៉ា សាខន, ចៅក្រម ធូ មណី" (**បណ្តឹងជំទាស់របស់អៀង ធីរិទ្ធ**)[1]។ មេធាវីការពារក្តីលោកនួន ជា និង លោកអៀង សារីបានដាក់ពាក្យបណ្តឹងជំទាស់ស្រដៀងគ្នានេះដែរជាបន្តបន្ទាប់គ្នា[2]។ នៅថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១,សហព្រះរាជអាជ្ញាបានឆ្លើយតបដោយដាក់ថា"ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងជំទាស់ចៅក្រមជម្រះរបស់ អៀង ធីរិទ្ធ, អៀង សារី និង នួន ជា" (**ចម្លើយតបរួម**)[3] ។ ចម្លើយតបរួមនេះត្រូវបានជូនដំណឹងដល់បណ្តាភាគីនៅថ្ងៃបន្ទាប់គឺថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១។

## II សេចក្តីសន្និដ្ឋានតប

២. មេធាវីការពារក្តីយល់ឃើញថា សហព្រះរាជអាជ្ញាមានការភាន់ច្រឡំទៅនឹងអំណះអំណាងរបស់មេធាវីការពារក្តីនៅក្នុងកថាខណ្ឌទី ៣នៃចម្លើយតបរបស់ខ្លួន។ មេធាវីការពារក្តីមិនបានតវ៉ាអំពីសមត្ថភាពនៃចៅក្រមជម្រះទាំងអស់នោះទេ។ ក្រៅពីនេះនោះ អំណះអំណាងដែលបានបង្ហាញថាអង្គជំនុំជម្រះសាលាដំបូងបានកំណត់រួចហើយនូវបញ្ហាជាច្រើននៅក្នុងសំណុំរឿងក្តីរបស់ ឌុចនោះថា វាមិនសូវសំខាន់ចំពោះមេធាវីការពារក្តីរបស់ឌុចទេ ហើយហេតុនេះមិនត្រូវតវ៉ាជំទាស់ដោយត្រឹមត្រូវដោយមេធាវីការពារក្តីរបស់ឌុចនោះទេ ប៉ុន្តែបញ្ហាដដែលនេះវាមានសារសំខាន់ណាស់

---

[1] បណ្តឹងជំទាស់ចៅក្រម នីល នុន, Silyvia Cartwright, Jean-Marc Lavergne, ចៅក្រម យ៉ា សាខន, ចៅក្រម ធូ មណី ចុះថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ២០១១ , ឯកសារលេខ: E28។

[2] ពាក្យបណ្តឹងជំទាស់បន្ទាន់របស់ក្រុមមេធាវីការពារក្តី ស្នើសុំជំទាស់ចៅក្រមជម្រះទាំងអស់ ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១១ និងញត្តិគាំទ្ររបស់ក្រុមការពារក្តីលោក អៀង សារី ចំពោះបណ្តឹងជំទាស់របស់អៀង ធីរិទ្ធស្នើសុំជំនួសចៅក្រមជម្រះដើម្បីឲ្យជំនួសចៅក្រមបំរុងវិញ ឬចៅក្រមបន្ថែមដែលជ្រើសរើសដោយគណៈកម្មាធិការរដ្ឋបាលរបស់តុលាការ ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១១។

[3] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងជំទាស់ចៅក្រមជម្រះរបស់ អៀង ធីរិទ្ធ, អៀង សារី និង នួន ជា ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១, ឯកសារលេខ: E55 ។

ចំពោះរឿងក្តីដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលនេះ។ បញ្ហាទាំងនេះដូចជាអត្ថិភាពនៃជម្លោះប្រដាប់អាវុធនៅកម្ពុជានៅចន្លោះឆ្នាំ១៩៧៥ និង ១៩៧៩ ដែលតម្រូវឱ្យភាគីទាំងសងខាងបង្ហាញភស្តុតាង ហើយដែលមិនត្រូវយកភស្តុតាងតែសហព្រះរាជអាជ្ញាតែម្ខាងប៉ុណ្ណោះនោះទេ។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចបញ្ហានេះដោយពុំមានបានស្តាប់អំណះអំណាងពីក្រុមមេធាវីការពារក្តីនោះទេ។ហេតុដូច្នេះក្រុមមេធាវីការពារក្តីនៅក្នុងសំណុំរឿងលេខ០០២ ពិតជាមានព្យសនកម្មដោយអយុត្តិធម៌ដោយសារតែបញ្ហាដូចគ្នាទាំងនេះវាមានសារសំខាន់ណាស់ចំពោះសំណុំរឿងក្តីនេះ។

៣. សហព្រះរាជអាជ្ញាអះអាងថា "ក្រុមមេធាវីការពារក្តី មិនបានជំទាស់នឹងសាលក្រមលើករណី ឌុចដែលថាចៅក្រមបានពិចារណាកត្តាខាងក្រៅ ឬកត្តាមិនសមស្របនោះឡើយ[4]"។ ជាថ្មីម្តងទៀតបញ្ហានេះ ផ្ទុយពីអំណះអំណាងរបស់ក្រុមមេធាវីការពារក្តី។ មានឧទាហរណ៍ជាច្រើនដែលក្រុមមេធាវីការពារក្តីឌុច មិនបានបានធ្វើអំណះអំណាងណាមួយជំទាស់ទៅនឹងករណីរបស់សហព្រះរាជអាជ្ញាព្រោះពួកគេប្រហែលជាមិនចាប់អារម្មណ៍ក្នុងការធ្វើដូច្នេះ។ ហេតុនេះហើយចៅក្រមនៅអង្គជំនុំជម្រះសាលាដំបូង មិនបានស្តាប់ភាគីទាំងសងខាងអំពីស្ថានភាពនេះឡើយ ហើយបានធ្វើការសន្និដ្ឋានអំពីអង្គហេតុ និងអង្គច្បាប់ដោយផ្អែកតែលើព័ត៌មានរបស់ភាគីតែម្ខាងប៉ុណ្ណោះ។ ក្នុងកាលៈទេសៈនេះ មេធាវីការពារក្តីយល់ឃើញថាវានឹងបង្កបញ្ហាចំពោះចៅក្រមនៅអង្គជំនុំជម្រះសាលាដំបូងក្នុងការលុបចោលនូវសេចក្តីសន្និដ្ឋានរបស់ខ្លួនលើអង្គហេតុ និងអង្គច្បាប់ដែលបានធ្វើរួចមកហើយក្នុងករណីឌុច និងក្នុងការធ្វើការសន្និដ្ឋានផ្សេងពីនេះក្នុងសំណុំរឿង០០២ ។ អង្គជំនុំជម្រះដែលមានចៅក្រមខុសពីមុន នឹងមិនត្រូវបានគេរារាំង ឬធ្វើឱ្យអាម៉ាស់ដោយសារតែការសម្រេចកាលពីមុនឡើយ ដូច្នេះពួកគេស្ថិតក្នុងលក្ខណ្ឌល្អប្រសើរជាងដើម្បីសម្រេចលើករណីទាំងនេះ។

៤. មេធាវីការពារក្តី យល់ឃើញទៀតថាអ្វីដែលពិសេសទាក់ទងនឹងករណីនេះ គឺថាវាមិនមែនមានតែចៅក្រមម្នាក់ទេដែលបានបង្កើតបានជាអង្គជំនុំជម្រះលើករណីឌុច ប៉ុន្តែវាគឺជាអង្គជំនុំជម្រះសាលាដំបូងទាំងមូលដែលសម្រេចលើករណី០០១។ ដូច្នេះនៅពេលដែលសហព្រះរាជអាជ្ញាអះអាងថា "គ្មានករណីព្រហ្មទណ្ឌអន្តរជាតិណាមួយដែលលើកយោងដោយភាគីបានបង្ហាញយ៉ាងដូច្នេះឡើយ[5]" នោះ

[4] ចម្លើយតបរួម, កថាខណ្ឌទី៩។

[5] ចម្លើយតបរួម, កថាខណ្ឌទី១១។

វាគ្មានករណីណាមួយដែលទាក់ទងទៅនឹងចៅក្រមទាំងអស់ នឹងត្រូវបានគេផ្លាស់ប្តូរឡើយ។ វាគឺជាការអះអាងរបស់មេធាវីការពារក្តីដែលថាបញ្ហានេះ បានធ្វើឱ្យករណីដែលពាក់ព័ន្ធក្លាយទៅជាករណីពិសេសខុសផ្លែកពីគេ ហើយតម្រូវឱ្យមានបណ្តឹងជំទាស់ប្រឆាំងចៅក្រមនៅអង្គជំនុំជម្រះសាលាដំបូងទាំងអស់នេះ។

## III. សំណើ

៥. អនុលោមតាមវិធាន ៣៤ (២) នៃវិធានផ្ទៃក្នុង មេធាវីការពារក្តីសូមស្នើជំទាស់ចំពោះចៅក្រមនៅអង្គជំនុំជ្រះសាលាដំបូង ដែលរួមមានចៅក្រម និល ណុន ចៅក្រម Sylvia Cartwright ចៅក្រម ធូ មណី ចៅក្រម Jean-Marc Lavergne និងចៅក្រម យ៉ា សុខន ដោយសារតែមានការលិចឡើងនូវភាពលម្អៀងចាប់តាំងពីមានការបង្ហាញពីភាពលម្អៀងប្រឆាំងជនជាប់ចោទរួចមក។

៦. អាស្រ័យហេតុនេះ មេធាវីការពារក្តីស្នើឱ្យដាក់ចៅក្រមបំរុងរបស់អង្គជំនុំជម្រះសាលាដំបូងជំនួសចៅក្រម និល ណុន ចៅក្រម Sylvia Cartwright ចៅក្រម ធូ មណី ចៅក្រម Jean-Marc Lavergne និងចៅក្រម យ៉ា សុខន ឬក៏ដាក់ជំនួសដោយចៅក្រមផ្សេងទៀតដែលជ្រើសរើសដោយគណៈកម្មាធិការរដ្ឋបាលតុលាការក្នុងចំណោមចៅក្រមនៅ អវតក ដូចដែលមានចែងក្នុងវិធាន៣៤ (៦) នៃវិធានផ្ទៃក្នុង។

| ភាគី | កាលបរិច្ឆេទ | ឈ្មោះរបស់មេធាវី | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|---|
| សហមេធាវីអន្តរជាតិរបស់អ្នកស្រី អៀង ធីរិទ្ធ | ថ្ងៃទី ១ ខែ មីនា ឆ្នាំ២០១១ | Diana ELLIS, QC | ភ្នំពេញ | [signature] P.P |